# កិច្ចសម្ភាសរបស់លោកយាយ សៅ សឿន

ក៖ អ្នកសម្ភាសនឈ្មោះហេង សុជីវី ខ៖ អ្នកត្រូវគេសម្ភាសឈ្មោះ សៅ សឿន

ក៖ ចាសជាដំបូងជំរាបសួរលោកយាយ!
ខ៖ ចាសចៅអាយុវែងចៅ!
ក៖
ចាសនៅក្នុងថ្ងៃនេះចៅមានឳកាសមកសម្ភាសដល់លោកយាយហើយចៅបានធ្វើការងារស្មគ្រចិត្តរបស់គំរោងរបស់ខាងសាលាBYUនៅសហរដ្ឋអាមេរិកលោកយាយហើយគំរោងមួយហ្នឹងបានចង់ជួយចង់ក្រង់ពង្សប្រវត្តិជីវិតរបស់ចាស់ៗកាលពីជំនាន់មុនលោកយាយដែលគាត់បានធ្លាប់ឆ្លងកាត់ជីវិតនឹងបទពិសោធន៍ដែលគាត់បានជួបកាលពីមុនមកតើគាត់បានមានជីវិតបែបណាហើយតើគាត់មានប្រវត្តិនិងពង្សសារតារបស់គាត់បែបណាដើម្បីអោយយើងបានតភ្ជាប់អំពីសម័យចាស់ៗមកដល់សម័យឥឡូវកុំអោយវាបានបាត់បង់ណាលោកយាយ។
ខ៖ ចាស!
ក៖
ចាស!ចឹងនៅក្នុងថ្ងៃនេះចៅមានឳកាសដើម្បីមកសម្ភាសដល់លោកយាយចឹងតើលោកយាយធ្វើការអនុញ្ញាតដើម្បីអោយចៅធ្វើការសម្ភាសដល់យាយនិងថតរូបរបស់លោកយាយយកទៅដាក់នៅក្នុងវេបសាយរបស់ខាងសាលាដើម្បីទុកអោយកូនចៅជំនាន់ក្រោយគេចូលទៅស្តាប់សម្លេងរបស់លោកយាយនៅក្នុងថ្ងៃនេះបានដែរឬទេលោកយាយ?
ខ៖ បានតើចៅ!
ក៖
ចាសចឹងជាដំបូងនៅក្នុងការសម្ភាសចឹងថ្ងៃនេះគឺជាថ្ងៃទី២២ខែ៨ឆ្នាំ២០១៨ហើយមានឈ្មោះថាហេងសុជីវីគឺជាអ្នកសម្ភាសហើយចុះចំណែកឯលោកយាយវិញតើលោកយាយមានឈ្មោះអ្វីដែរទៅលោកយាយ?
ខ៖ ខ្ញុំមានឈ្មោះថា សៅ សឿន។
ក៖
ចាសលោកយាយចឹងតើលោកយាយមានឈ្មោះហៅក្រៅផ្សេងក្រៅពីហ្នឹងដែរឬក៏អត់?
ខ៖ មាន! គេនែកឪម្តាយរបស់ខ្ញុំបានដាក់ឈ្មោះអោយសៅ
សឿនហើយខ្ញុំគេហៅថាយាយ ឌុបនៅពេលសព្វថ្ងៃនេះ។
ក៖ ចាស!លោកយាយមានរហស់នាមក្រៅចឹងណ៎?
ខ៖ ចាស!
ក៖
ហើយចឹងរហនាមក្រៅនិងតើនរណាគេបានដាក់ឈ្មោះនិងអោយដល់លោកយាយដែរតើជាអ្នកជិតខាងអ្នកដែលបានស្គាល់គ្នាឬក៏ជានរណាដែរលោកយាយ?
ខ៖ អ្នកជិតខាង អ្នកស្គាល់គ្នា បងៗ។
ក៖ បងៗទៀតយាយណ៎?
ខ៖ ចាស!
ក៖
ហើយទៅលោកយាយឈ្មោះហ្នឹងបានត្រូវជាមួយនិងអត្តសញ្ញាណប័ណ្ណរបស់លោកយាយដែរឬទេឈ្មោះនុង?
ខ៖ ត្រូវៗ!
ក៖ ចាស!ទាំងនាមត្រកូលរបស់លោកយាយដែរហ៎?
ខ៖ ចាស!

កៈ
ចាស!ហើយឈ្មោះនេះគាត់មានបានប្រាប់លោកយាយថាវាមានអត្តន័យយ៉ាងម៉េចដែរឬទេចាំម៉ាក់របស់លោកយាយដែលបានដាក់ឈ្មោះនេះអោយ?
ខៈ
ហឹម!មិនបានដឹងដែលចៅគាត់ប្រហែលជាដាក់នុងអោយបានជួននឹងគាត់ឈ្មោះសៅ សឿនចឹងណាអោយបានជួន
ឈ្មោះរបស់គាត់ចឹងគាត់បានដាក់ចឹងទៅ។
កៈ
ចាស!លោកយាយចឹងមកដល់ពេលសព្វថ្ងៃនេះតើលោកយាយមានព្រះជនបានប៉ុន្មានហើយយាយ?
ខៈ យាយ៦៩ហើយចៅ។
កៈ ចឹងយាយបានកើតនៅក្នុងឆ្នាំណាដែរ?
ខៈ មិនបានដឹងថានៅក្នុងឆ្នាំណានោះទេចៅ។
កៈ ចុះឆ្នាំខ្មែររបស់យើងយាយ?
ខៈ ឆ្នាំខ្មែរយើងយាយបានកើតនៅក្នុងខែពិសាខ ថ្ងៃអាទិត្យនៅក្នុងឆ្នាំខាល។
កៈ
ចាសយាយហើយយាយអឺ!...ដូចជាចង់ចាំកាលពីមុនលោកយាយបានរស់នៅឯណាហើយដល់លោកយាយមានស្រុកកំណើតនៅឯណា?
ខៈ ស្រុកកំណើតរបស់ខ្ញុំនៅឯភូមិពាយ ឃុំផាយ ស្រុកកំចាយមា ខេត្តព្រៃវែង។
កៈ
ចាសលោកយាយមករស់នៅទីលំនៅសព្វថ្ងៃនេះវិញតើលោកយាយមានទីតាំងរស់នៅឯណាដែរលោកយាយ?
ខៈ ទីតាំងនៅឯក្នុងវត្តស្រះចកនិងណាចៅ។
កៈ
ចាសបានប៉ុន្មានឆ្នាំដែរហើយលោកដែលលោកយាយបានផ្លាស់មករស់នៅឯក្នុងទីនេះ?
ខៈ ចៅអា!យាយបានដូចជាភ្លេចដែរហើយ!
ប្រហែលជាបានតាំងពី១២អីមកហើយ។
កៈ
ចឹងកាលពីសម័យជំនាន់ពីមុននុងលោកយាយបានរស់នៅឯស្រុកកំណើតនោះបានយូរមកហើយត្រូវអត់លោកយាយ?
ខៈ ត្រូវហើយចៅ!
កៈ ហើយលោកយាយមានឪពុកម្តាយគាត់ឈ្មោះអ្វីដែរ?
ខៈ ឪពុកម្តាយរបស់ខ្ញុំគាត់ឈ្មោះ តាសៅនិងម្តាយរបស់ខ្ញុំឈ្មោះយាយសឿន។
កៈចាស!តើឪពុកម្តាយរបស់លោកយាយសព្វថ្ងៃគាត់បានស្លាប់អស់ហើយ?
ខៈ អូ...!គាត់បានស្លាប់ទៅអស់យូរហើយនាង។
កៈ បានរយៈពេលបានប៉ុន្មានឆ្នាំហើយ?
ខៈ
អូ!បានយូរឆ្នាំហើយតាំងពីខ្ញុំបានអាយុ១៤ឆ្នាំម៉េសនេះឪពុករបស់ខ្ញុំណាដល់ពេលចំណែកឯខាងម្តាយខ្ញុំវិញគាត់បានទើបតែស្លាប់នៅពេលដែលខ្ញុំនេះបានមេម៉ាយហើយនុងទេបានប្រហែលជា៣០ឆ្នាំហើយ។
កៈ
ចាស!លោកយាយកាលនុងលោកយាយបាននៅទាន់គាត់ចឹងពេលនុងប្រហែលជាលោកយាយបានអាយុបានប៉ុន្មានឆ្នាំដែរ?
ខៈ ខ្ញុំទាន់ម្តាយរបស់ខ្ញុំគឺខ្ញុំមានអាយុបាន៣០ឆ្នាំ។
កៈ ចាស!

ខ៖
ចឹងកាលពីជំនាន់មុខឪពុកម្តាយរបស់លោកយាយគាត់បានប្រកបមុខរបអ្វីដែរ
ដើម្បីចិញ្ចឹមគ្រួសារនិងជីវិតដែរលោកយាយ?
ខ៖ មុខរបរបស់គាត់ជាកសិករធ្វើស្រែចៅ។
ក៖ នៅឯស្រុកកំណើតនុងលោកយាយណ៎?
ខ៖ ចាស!!
ក៖ ចាស!ហើយគាត់មានបានផ្តែផ្តាំអីដល់យាយដែរឬទេ?
ខ៖
ផ្តែផ្តាំដែរថាអោយអត់ពីគាត់ទៅអោយយើងបានថែរក្សាបងប្អូនណាអោយយើង
បានមើលការខុសត្រូវពេលដែលអត់ពីគាត់ទីណាអោយចេះស្រលាញ់គ្នាអោយចេះ
រាប់រកគ្នាទាំងញាតិជិតខាងទាំងបងទាំងប្អូនចឹងណាចៅ។
ក៖
ចាសលោកយាយចឹងលោកយាយបានគិតថាឪពុកម្តាយរបស់លោកយាយគាត់គឺ
ជាមនុស្សបែបណាដែរ?
ខ៖ ឪពុកម្តាយរបស់ខ្ញុំគឺជាមនុស្សល្អស្លូតបូតមានញាតិគេស្រលាញ់គ្រាប់គ្នាចៅ។
ក៖
ហឹម!ហើយលោកយាយមានបាននៅចាំថ្ងៃខែឆ្នាំកំណើតរបស់ឪពុកម្តាយរបស់លោ
កយាយដែរឬទេ?
ខ៖ អត់បាននៅចាំនោះទេចៅ!ឪពុករបស់ខ្ញុំ
ចាស់!មកយកម្តាយរបស់ខ្ញុំក្មេងហើយខ្ញុំវានៅវ័យតូចចឹងគាត់ក៏បានស្លាប់ទៅចោ
លខ្ញុំណាចឹងទៅគាត់បានមេម៉ាយ! មកយកម្តាយរបស់ខ្ញុំនៅក្រមុំ។
ក៖ អូ!
ខ៖ ម្តាយរបស់ខ្ញុំគាត់!
គាត់គឺជាអ្នកក្រហើយឪពុករបស់ខ្ញុំគឺជាអ្នកធូធា!ដល់ដែលពេលប្រពន្ធរបស់គាត់
ងាប់ទៅបានទៅស្តីដណ្តឹងម្តាយរបស់ខ្ញុំក៏គាត់ព្រមយកទៅព្រោះអីគាត់ក្រទោះបី
យើងនៅរកចាំអ្នកមានក៏គេមិនបានទៅយកគាត់នោះដែរ!
នេះគាត់បានប្រាប់ថាចេះ!ចឹងបានសុខចិត្តយកម៉េម៉ាយចាស់ហ្នឹងចុះចឹងណាចៅ
។
ក៖
ចាស!ចឹងកាលសម័យនុងលោកតាហើយនិងលោកយាយដែលបានត្រូវជាឪពុក
ម្តាយរបស់លោកយាយនុងគាត់នៅអ្នកភូមិជាមួយគ្នាឬក៏យ៉ាងណាដែរទៅយាយ?
ខ៖ នៅឆ្ងាយពីគ្នាយាយ! ឪពុករបស់គាត់នៅគ ភូមិជាយ
ហើយម្តាយខ្ញុំនៅគច្រៀត ភូមិលហើយ នៅក្នុងស្រុកក្រចៀតនុងណា។
ក៖
ចាសលោកយាយហើយចឹងកាលនុងលោកយាយមានដឹងថាឪពុកម្តាយរបស់លោ
កយាយបានរៀបការតាមផ្លូវច្បាប់ឬក៏គាត់បានស្រលាញ់គ្នាដែរទៅលោកយាយ?
ខ៖ រៀបការតាមផ្លូវច្បាប់! ចៅ!។
ក៖
ចាស!ហើយមកដល់ពេលលោកយាយវិញតើលោកយាយមានបាននៅចាំអំពីជីដូន
និងជីតារបស់លោកយាយដែរឬទេ?
ខ៖
ខ្ញុំអត់ស្គាល់នោះទេខាងឪរបស់ខ្ញុំណាដែលជាឪពុកនិងម្តាយរបស់គាត់ណាខ្ញុំបាន
ស្គាល់តែយាយខាងម្តាយឈ្មោះថាលោកយាយមាសគាត់!...បានស្គាល់តែមួយនាក់
ហ្នឹងនោះទេយាយហ៎។
ក៖ ចាស!

ខៈ
ព្រោះអីយាយកាលនុងខ្ញុំបានកើតមកបានតែប៉ុន្មានឆ្នាំហើយក៏យាយគាត់បាន
ស្លាប់ទៅ។
កៈ ចឹងលោកយាយបានកើតទាន់តែលោកយាយតែម្នាក់នោះទេ?
ខៈ ទាន់តែយាយម្នាកនោះទេ។
កៈ កាលនុងយាយមានអាយុបានប៉ុន្មានដែរទៅយាយ?
ខៈ
ហឹម!កាលនុងតូចណាស់!ដែលបានទាន់យាយនុងប្រហែលជាអាយុបាន១០ឆ្នាំ
នោះទេវារាងស្រពិតស្រពិលណានាង។
កៈ
ចឹងលោកយាយអាចដឹងថាកាលនៅជំនាន់នុងតើគាត់មានចរិតលក្ខណៈយ៉ាង
ណាដែរសំរាប់លោកយាយដែរ?
ខៈ
ហឹម!ចរិតគាត់ល្អណាស់!យាយនុងខ្ញុំបានកើតនៅរាងតូចមែនតែចរិតរបស់គាត់
ល្អស្រលាញ់ចៅណាស់កូនចៅទាំងអស់គាត់មិនដែលចេះជេរចេះរ៉ៃនោះទេ!
នេះខ្ញុំបាននៅទាន់គាត់។
កៈ ចាស!ហើយគាត់មានមុខរបរអ្វីដែលលោកយាយ?
ខៈ
ធ្វើស្រែជាអ្នកក្រជាទីបំផុតយាយនៅខាងយាយខ្ញុំនេះនុងដែលយាយនៅខាងម្តា
យហ្នឹងណា។
ក ៖ ហឹម!
ខៈ
តែខាងឪនោះខ្ញុំអត់បានស្គាត់ទាំងអស់មិនបានដឹងថាមានមុខយាយតាយ៉ាង
ម៉េចទេ។
កៈ
ហឹម!ចឹងលោកយាយកាលនុងគាត់នៅពីកំណើតកើតជាមកកាលដែលគាត់នៅ
ពីក្មេងតើជីវិតរបស់លោកយាយនុងគាត់មានជីវិតបែបណាទេយាយ?
ខៈ ជីវិតរបស់ខ្ញុំផ្ទាល់ហេស?
កៈ
ជីវិតរបស់លោកយាយត្រូវជាលោកយាយខាងម្តាយដែលលោកយាយបានកើតទា
ន់គាត់ណាតើគាត់មានបានប្រាប់អំពីជីវិតរបស់គាត់កាលនៅពីក្មេងៗដល់លោក
យាយដែរឬទេ?
ខៈ គាត់និយាយប្រាប់ដែរ។គាត់ថាយាយលំបាកលំបិនណាស់!
កើតមកចំតែកូនអ្នកក្រខ្សត់ចឹងយាយបានដើរទៅធ្វើតែខ្ញុំគេ!
ចិញ្ចឹមកូន!គាត់បាននិយាយតែប៉ុណ្ណឹងចឹងហើយខ្ញុំបាននៅចាំតែប៉ុណ្ណឹងនោះទេ
យាយ។
កៈ
ចាស!លោកយាយចឹងបន្ទាប់ពីនុងមកគាត់មានបានប្រាប់និងធ្វើការប្រៀនប្រ
ដៅនូវដំបូងមានល្អៗតើលោកយាយមានបាននៅចាំដែរឬទេលោកយាយ?
ខៈ ហឹម!ដំបូងមានរបស់គាត់ល្អៗណាស់!
ពេលដែលខ្ញុំបានធំដឹងក្តីគាត់បានប្រាប់ថាអោយខំរកស៊ីអោយវាមានបានអីនឹង
គេកុំខ្ជិលកូន! ហើយចេះរាប់ញាតិនៅក្នុងស្រុកនៅក្នុងភូមិកុំកាចកុំអីកូន។
កៈ ហឹម!
ខៈ ប៉ុន្តែគាត់មិនអោយខ្ញុំរៀននោះទេ។
កៈ មិចចឹងលោកយាយ?
ខៈ
គាត់បានថាអោយរៀនធ្វើអីទេកូនស្រីនោះចឹងបើសិនជារៀនក៏មិនដឹងជាបាន

ស្ទីដែរវាបានតែត្រឹមផ្ញើសំបុត្រអោយប្រុសឈ្មោលនោះទេចឹងហើយមិនបាច់រៀននោះទេ! គាត់បាននិយាយចឹងតែម្តង។

ក៖ ហើយលោកយាយកាលនុងចង់រៀនអត់?

ខ៖

ចង់ដែរតែម្តាយឪរបស់ខ្ញុំមិនអោយរៀនកាលនុងបើសិនជាម្តាយអោយរៀនតែសំរាប់ឪមិនអោយហើយម្តាយខ្ញុំកាលនុងគាត់បានស្តាប់ឪរបស់ខ្ញុំបើសិនជាឪរបស់ខ្ញុំបានថាម៉េចគាត់បានតាមឪរបស់ខ្ញុំចឹង។

ក៖

ចាស!ហើយលោកយាយចឹងកាលនៅពីក្មេងតើលោកយាយមានក្តីស្រម៉ៃថាធំឡើងចង់ធ្វើអ្វីឬក៏អត់ទេ?

ខ៖ ចង់! ធ្វើការលក់ដូរកាលនុង។

ក៖ ហឹម!

ខ៖

ព្រោះអីយើងកាលនុងវាអត់បានចេះអក្សរអីទេចឹងយើងបានលក់ដូរអីបានបន្តិចបន្តួចអីនុងអាចលក់កើតណានេះបាននឹកនៅក្នុងខ្លួនណា។

ក៖ ចាស!

ខ៖ តែនេះវាមិនបានដូចជាគោលបំណង់។

ក៖ អឹម!...មិចទៅលោកយាយ?

ខ៖ វាបានតែធ្វើស្រែ! ។

ក៖ ចាស!

ខ៖ ចាស!

ក៖ ហើយលោកយាយបានការនៅក្នុងឆ្នាំណាដែរទៅលោកយាយ?

ខ៖

ហឹម!កាលដែលការនុងមិនបានដឹងថានៅក្នុងឆ្នាំណានោះទេហ្នឹងណានាងខ្ញុំនេះក៏វាបានភ្លេចដែរទៅមិនបានជាគិតអីនោះទេ!។

ក៖ ប្រហែលជានៅក្នុងជំនាន់សង្គមរាស្ត្រជានិយមណ៎លោកយាយណ៎?

ខ៖ អឺឆ្នាំ!ទំលាក់សីហនុហ្នឹង!ចឹងហើយ។

ក៖

ចាស!ហើយកាលនុងលោកយាយបានស្រលាញ់គ្នាឬក៏ឪពុកម្តាយគាត់គឺជាអ្នកដែលបានទុកដាក់អោយដែលលោកយាយ?

ខ៖ អូ!...ឪពុកម្តាយទេនាង!មិនទៅតាមខ្លួនឯងនោះទេ។

ក៖ ចឹងលោកយាយអត់ដែលបានស្គាល់លោកតាសោះតែម្តង?

ខ៖ អត់!

ស្គាល់ប៉ុន្តែខ្ញុំអត់ស្គាល់គេមិនដឹងថាស្រលាញ់អីនោះទេប៉ុន្តែកាលជំនាន់ខ្ញុំនេះវាកើតខ្មែរក្រហមណាហើយខ្ញុំវាក្រមុំ២នាក់ដល់កើតខ្មែរក្រហមនៅពេលយប់ៗគេបានលួចចូលមកគេចេះតែមកសុំឪពុកនិងម្តាយខ្ញុំនឹងយកខ្ញុំហ្នឹងទៅធ្វើជាពេទ្យនៅឯក្នុងព្រៃដល់ចឹងម្តាយរបស់ខ្ញុំនេះគាត់ភ័យ!

គាត់ថាទុកមិនកើតនោះទេគេបានមកសុំ២ទៅ៣ដងហើយ។

ក៖ ហឹម!

ខ៖

ដល់ចឹងបានរៀបកូនអោយបានមានគូចឹងទៅបើសិនជាមានគូគេលែងមកសុំយើងហើយចឹងក៏ម្តាយខ្ញុំអោយគេទៅ!អោយគេក៏ម្តាយរបស់ខ្ញុំមិនបានសួរខ្ញុំដែលគាត់បានអោយរៀបការចឹងក៏បានការទៅចឹងនោះទេ។

ក៖

ចាសលោកយាយចឹងគាត់បានអោយលោកយាយបានការហើយចឹងកាលនុងលោកយាយបានស្នាគចិត្តអត់លោកយាយ?

ខ៖ ទេនាង!កាលដែលបានការហើយចឹងចេះតែប្រឹងទ្រាំនិងគេទៅ! ម្ដាយឪថាម្ដាយការហើយបើសិនជាបន្តិចរត់ទីនេះបន្តិចរត់ទៅឯនោះមិនបាននោះទេ ម្ដាយគ្មានអ្វីសងគេទេ។
ក៖ ចឹងកាលនុងគេបានបង្គាប់ថ្លៃទឹកដោះណំលោកយាយ?
ខ៖ ចាសកាលនុងគេបានបង្គាប់ថ្លៃអាហ្នឹងណា។
ក៖
ហឺម!ហើយចឹងកាលនុងលោកយាយបានរៀបការអីត្រឹមត្រូវទៅតាមប្រពៃណីអីទាំងអស់?
ខ៖ អូ!កាលនុងបានការអីត្រឹមត្រូវណាស់នាង! បានភ្ជាប់ពាក្យពាក់កណ្ដាលឆ្នាំអីចឹងទៅបានជាយើងការ។
ក៖ ចាស!ហើយពេលនុងលោកតាគាត់មានឈ្មោះអ្វីគេដែលទៅលោកយាយ?
ខ៖ ឈ្មោះ ថុញ។
ក៖ ចាស!
ខ៖ ឪរបស់គេឈ្មោះ គៀន។
ក៖ អូ!ហើយគាត់គឺជាអ្នកស្រុកនៅជាមួយគ្នាដែរ?
ខ៖ អូ...នៅជាអ្នកស្រុកជាមួយដែលប៉ុន្តែវានៅឆ្ងាយពីគ្នា។
ក៖
ចាសហើយចឹងលោកយាយបានជួបលោកតាដំបូងនៅពេលការតែម្ដងឬក៏យ៉ាងម៉េចដែរទៅលោកយាយ?
ខ៖ នៅពេលការតែម្ដងនាង។
ក៖ មិនបានជួបមុខគ្នា។
ខ៖ ចាស
ក៖ ចឹងលោកយាយមានបានកូនប៉ុន្មាននាក់ដែរ?
ខ៖ ខ្ញុំមានកូន៧នាក់!។
ក៖ ៧នាក់លោកយាយ?
ខ៖ ចាស!
ក៖ ចឹងគាត់មានឈ្មោះអ្វីគេខ្លះដែរទៅលោកយាយ?
ខ៖
នាងអា!!ពេលដែលបានកើតមកងាប់នុងក៏មិនបានដាក់ឈ្មោះទៅណា!កើតមកងាប់ៗ២ទៅ៣ខែនុងណាក៏មិនបានទាន់ដាក់ឈ្មោះកូនទៅ។
ក៖ហឹម!
ខ៖ ហើយដល់ពេលកាលនៅក្នុងជំនាន់ពពតនេះក៏ងាប់មួយនាក់ទៀត។
ក៖ ហឹម!
ខ៖ ងាប់មួយនុងអានុងមានឈ្មោះថាអាញ៉ាន។
ក៖ ហឹស!
ខ៖ហើយដល់ពេលមកដល់សព្វថ្ងៃនេះនៅ៣នាក់នាង។
ក៖ ចាស!
ខ៖ នែកឈ្មោះមីបងគេនោះឈ្មោះមីនឿន មកប្រុសឈ្មោះអា ភឿន មកមីស្រីក្រោយនេះឈ្មោះមីនួន មាន៣នាក់នុងដែលបាននៅ។
ក៖
ចាសចឹងលោកយាយកូនរបស់លោកយាយទាំង៣នាក់នុងគាត់បានសិក្សាដល់កំរិតណាដែលទៅលោកយាយ?
ខ៖ នាង! ខ្ញុំនេះម៉េម៉ាយចឹងហើយគ្មានបានអោយកូនបានទៅសិក្សានោះទេ! ចេញពីពពតមកនុងវាគ្មានអ្វីដើម្បីហូបវាគ្មានអង្ករមួយគ្រាប់នៅសល់សោះចឹងបានចេះតែដើររកនៅក្នុងព្រៃអីចឹងទៅដើម្បីយកមកបបរអោយកូនបានហូប! ដល់១ឆ្នាំឡើងទៀតក៏ខ្ញុំនេះបានធ្វើស្រែវាអត់បាន!ព្រោះអីយើងនេះវាអត់បានមានក្របីគោអីទៅធ្វើនិងគេនោះទេចឹងហើយខ្លាចវាមិនគ្រាប់មិនគ្រាន់ចឹងហើយ

បានទៅដើរលក់អីចឹងដើម្បីយកមកផ្សំគ្នាដើម្បីយកមកអោយកូនបានហូបចឹង ហើយកាលនុងមិនបានអោយកូនទៅរៀននោះទេ! ។
ក៖ ហឹម!ចឹងកាលនុងលោកតាគាត់មានបញ្ហាអីគេដែលលោកយាយ?
ខ៖ កាលនុងមិនមានបញ្ហាអីនោះទេកាលនុងពពតវាសំលាប់។
ក៖
កាលនុងគាត់បានចោលលោកតាថាម៉េចដែរឬគេបានយកគាត់ទៅតែម្តងលោកយាយបានដឹងអំពីគាត់ទេកាលនុង?
ខ៖
នែក!កាលនុងគេបានមកយកយើងហើយយើងនេះបានគេញព្រោះអីយើងបានដឹងខ្លួនណាហើយពេលនុងយើងនេះបានរត់គេចទៅរត់ជាន់មីងគេនោះចឹងក៏ងាប់ទៅនាង។
ក៖ លោកយាយបានឃើញផ្ទាល់ភ្នែកឬក៏យ៉ាងម៉េចដែរទៅយាយ?
ខ៖ បានឃើញផ្ទាល់ភ្នែកនាង! ខ្ញុំបានឃើញ!
ហើយខ្ញុំបានមានរបួសមកទាល់តែឥឡូវនេះណា! ។
ក៖
អូយ!សូមទោសលោកយាយដែលបានលឺចឹងហើយចឹងគេបានជំលៀសលោកយាយទៅឯណាដែរទៅចឹង?
ខ៖
គេបានជំលៀសខ្ញុំទៅឯខាងលើដល់ឯខាងលើនៅឯថ្ងៃទាល់រលូចហើយគេបានជំលៀសយើងបានទៅឯព្រៃនរកក្រៅ!
នៅឯព្រៃនរកក្រៅនៅក្នុងស្រុកយើងនេះណានៅក្នុងខេត្តត្បូងឃ្មុំនេះណា! ។
ដល់ទៅពេលបានទៅនៅឯនុងចឹងទៅពពតគេចេះតែទៅតាមដានយើងចឹងណា ហើយខ្ញុំកាលនុងបានឯខាងអង្គភាពនាង!ដែលគេបានយកទៅហ្នឹងណាហើយដល់នេះចឹងទទៅគេបានចេះតែតាមដានៗចឹងក៏ប្តីរបស់ខ្ញុំនុងយកខ្ញុំចូលទៅក្នុងព្រៃហើយរត់។
ក៖ ហូស!!...ចាស!ហើយដល់ពេលរត់ចឹងទៅគាត់ក៏បានរត់ជាន់គ្រាប់មីងចឹងទៅ។
ខ៖ គ្រាប់មីងគេនុងគេបានដាក់មួយចំការៗណាចំការមីងគេនុងណា។
ក៖ ចាស!យាយ
ខ៖ ហើយក៏ស្លាប់នៅក្នុងព្រៃនុងចឹងទៅ។
ក៖
អូយ!ស្រើយណាស់កាលនុងហើយលោកយាយចេះអត់អីដូចថាលោកយាយបានរួចពីជីវិតណាចេះកាន់ដៃអ្នក២នាក់ហើយស្លាប់តែលោកតា?
ខ៖ ស្លាប់តែគាត់និងកូន១នាក់ទៀត។
ក៖ អួយ!...លោកយាយខ្លោចចិត្ត!!ចឹងលោកយាយបានកូនប៉ុន្មាន?
ខ៖ កូន៧។
ក៖ កាលនុងក្នុងសម័យពពតលោកយាយមានកូនប៉ុន្មាននាក់?
ខ៖
កូន៧នាក់នុង!ហើយកូនតូចៗនោះចឹងកូនវានៅតូចចឹងបានបីហើយអី!នៅក្នុងព្រៃនោះវាគ្មានទឹកដោះឯណាអោយបៅបើសិនជាអត់បាយអីផងឃ្លានផងនោះ!
ចឹងក៏កូននុងវាបានឈឺហើយវាគអាចម៍ក៏ងាប់ទៅកាលនុងវាគ្មានពេទ្យអី។
ក៖
ចឹងកាលនុងបាននៅសល់កូនប៉ុន្មានដែរ?ហើយចឹងនៅពេលដែលបានរត់ចូលនៅក្នុងព្រៃជាមួយគាត់នុងបាននាំកូនទៅប៉ុន្មាននាក់ដែរ?
ខ៖ ទាំង៧។
ក៖ អូទាំង៧នាក់!
ខ៖ ចាស!
ក៖ អូយយាយ!

ខៈ
ហើយចឹងក៏បានងាប់ទៅ!បានងាប់អាតូចៗនុងទៅនៅតែអាត្រីសៗហ្នឹងងាប់អា
រាងធំនោះមួយអាញ៉ានហ្នឹងដែលបងគេ។
កៈ អូយ!...ចឹងនៅសល់ប៉ុន្មានដែរ?
ខៈ មកដល់ពេលឥឡូវបាននៅសល់៣នាក់។
កៈ
ចឹងនៅពេលត្រូវជាន់គ្រាប់បែបនុងគឺនៅសល់តែកូន៣ព្រមទាំងលោកយាយ១
នាក់ទៀតនៅ៤នាក់ទេ?
ខៈ ចាស!
កៈ
អូយ!លោកយាយអើយ!ចឹងលោកយាយបានធ្វើយ៉ាងម៉េចទៅបន្ទាប់មកទៀត?
ខៈ ដល់មក!
ដើរមកយើងបានត្រូវគ្រាប់នុងយើងនេះបានដើរទៅឯណារួចដល់ចឹងពួកពពត
នុងវាបានមកបរទេះមកក្នុងព្រៃនោះចឹងវាបានឃើញដល់វាបានឃើញយើងក៏វា
បានលើកដាក់លើរទេះហើយក៏ពេលលើកដាក់នៅលើករទេះចឹងមកក៏វាបានយក
យើងមកដាក់នៅឯព្រៃកោងកាងឯនេះនៅភូមិសឹងនេះ។
កៈ នៅកោះកុងឬក៏នៅឯណា?
ខៈ អត់នោះទេនៅកោងកាងភូមិសឹងនេះ។
កៈ នៅភ្នំពេញឬក៏នៅឯណាដែរយាយ?
ខៈ អត់ភ្នំពេញនោះទេនៅឯខេត្តកំពង់ចាម។
កៈ អូចាស!
ខៈ
ហ្នឹង!គេយកមកទៅគេបានចាក់ថ្នាំអីអោយចឹងតែគេបានចាក់ថ្នាំទឹកដូងអីចឹង
អោយណា។
វាបានចាក់ថ្នាំទឹកដូងអីចឹងទៅហើយវាបានអោយបាយហូបចឹងទៅ។
កៈ ហឹម!ចឹងបានប៉ុន្មានថ្ងៃដែលវាបានជាហើយមានកំលាំងដើរបាន?
ខៈហឹម!មិនមែនប៉ុន្មានថ្ងៃនោះទេនាង!
គេបានយកទៅឃុំឃាំងនោះបានជិត១ខែដែរ។
កៈ ជាមួយកូនជាមួយអីទាំងអស់?
ខៈ ជាមួយកូននុង។
កៈ ចាស!
ខៈ វាមិនយកទៅវៃចោលដែរប៉ុន្តែបានពេទ្យនុងគេជួយខ្ញុំនៅ!
ប្រើងលូនទៅដាក់ដាំបាយអោយគេនេះចឹងនៅស្នាមនៅក្បាលជង្គន់នេះចឹងឡើង
សន្លាក់ហើយនេក។
កៈ ចាស!
ខៈ
ហើយលូនជួយដាំស្លគេចឹងទៅ!ហើយកាលនុងពេទ្យគេមានតែ៣នាក់ហើយស្រីៗ
មានប្រុស១នាក់ចឹង៣ហើយចឹងខ្ញុំបានជួយដាំស្លនិងជួយរែងអង្គអោយគេចឹងពា
ពតនុងបើកឡានទៅយកខ្ញុំអាកូនឡានតូចនុងបានគុណពេទ្យនុងណាចឹងអ៊ុំខ្ញុំ
សូមទុកហើយ!ព្រោះគាត់ជួយដាំស្លបើសិនជាយើងនរណាផ្សេងទៀតក៏យកទៅ!
គេថាចឹងហើយខ្ញុំក៏បានរស់ទៅហើយគេបានដឹកអ្នកផ្សេងៗទៀតទៅវៃចោល!
អស់ទៅ!។
កៈ ចាស!!ចឹងលោកយាយកាលនុងសំណាងលោកយាយ។
ខៈ សំណាងដែរនាង!។
កៈ
ចាសហើយលោកយាយពពតកាលនុងគេបានប្រើលោកយាយអោយធ្វើការងារអ្វី
គេខ្លះដែរ?

ខៈ នាង!គេប្រើអោយលើកដីគេបានប្រើអោយកាប់ចំការ! ដាំឪឡឹក ត្រសក់ពោត ស្ពងស្រូវស្រែ ស្ពងដក ច្រូត។
កៈហឹម!ទាំងយាយមានកូនខ្ចី?
ខៈ ទាំងនៅកូនខ្ចី! ។
កៈ ហឹម!
ខៈ
នៅកូនខ្ចីគេបានអោយរែងអង្ករគេមិនបានអោយទៅឆ្ងាយនោះទេណាគេបានអោយនៅរែងអង្ករដាក់ដាំបាយ។
កៈ
ចាសហើយចឹងនៅក្នុងសម័យនុងលោកយាយមានដែលបានធ្លាប់ចាញ់ទាស់អីទេ? មានដែលធ្លាប់ឈឺអីដែរយាយ?
ខៈ ឈឺនោះលែងនិយាយហើយនាង! ឈឺឡើង៣០ទៅ៤០នាក់នាងមានគ្រុនក្តៅ គ្រុនចាញ់ គេបានប្រាប់ថាគ្រុនចាញ់។
កៈ ទាំងយាយដែរ?
ខៈ ទាំងអស់ខ្ញុំក៏ចឹងដែរ។
កៈ ហើយបានអីលេបគេបានអោយអីដែរទៅ?
ខៈ
គេបានអោយថ្នាំគ្រាប់គេនុងបានលេបដែលនាង។ថ្នាំគ្រាប់នុងចេះតែបានលេបចឹងទៅ។
កៈ ហើយចឹងបានជាអត់ដែរឬទេយាយ?
ខៈ ជាបានខ្លះហើយងាប់បានខ្លះអីដែរនុងណា។
កៈ ចាស!ចឹងដូចជាយាយចឹងបានជាចឹងទៅ?
ខៈ ចាសខ្ញុំបានជាទៅ។
កៈ
ចាសហើយចឹងដល់នៅក្នុងសម័យនុងលោកយាយបានមានការតស៊ូច្រើនចឹងហើយគេមានដែលបានធ្វើបាបដល់លោកយាយដែរឬអត់?
ខៈ គេបានធ្វើដែល! គេបានធ្វើបាបដល់គ្រួសារខ្ញុំនុង! តែបើសិនជាខ្ញុំនេះវាបានគួសមនោះទេណាបើសិនជាខាងគ្រួសាររបស់ខ្ញុំនោះគេបានប្រើទាំងថ្ងៃទាំងយប់! គេប្រើទាំងថ្ងៃ។
កៈមិចចឹងលោកយាយកាលនុងគេបានចោលគេអីខ្លាំងមែន?
ខៈ
គេមិនបានចោលយើងនោះទេគេគ្រាន់តែប្រើយើងបើសិនជាយើងតមាត់គេនោះគឺស្លាប់! បើសិនជាយើងមិនតចេះតែទៅៗចឹងក៏រស់! ។
កៈ
ហឹម!ចាស!ចឹងកាលនុងគ្រួសាររបស់លោកយាយដែលបានទៅនុងគាត់អត់មានជំលៀសបែកគ្នានោះទេបានជំលៀសយកទៅជាមួយគ្នាតែម្តង?
ខៈ នែកគេជំលៀសបែកគ្នាណានាង ប្តីរបស់ខ្ញុំគេបានមករត់ចូលនៅក្នុងព្រៃទៅខ្ញុំរត់ទៅឯណាកូនបានទើបតែបានកើតបាន១០ថ្ងៃហើយគេបានគៀលទៅ!។
កៈហឹមចឹងធ្វើយ៉ាងម៉េចទៅបានជាលោកតាបានមកយកលោកយាយទៅបានចូលទៅឯក្នុងព្រៃនុង?
ខៈ
ដល់គាត់ចេះតែបានទៅស៊ើបសួរគេចឹងថាគេបានគៀលទៅឯខាងលើចឹងគាត់ក៏បានទៅស៊ើបខាងលើនុងចឹងនៅឯខាងលើនុងគេថាគេបានបញ្ជូនខ្ញុំនេះអោយទៅឯខាងព្រៃនរកហើយចឹង!គាត់ក៏បានទៅព្រៃនរកអោយខ្ញុំបានមក។
កៈ ហឹម!ចឹងកាលនុងបានទើបតែដាច់ឬក៏ជិតទើបតែចូលអាពាពត?
ខៈ អត់ទាន់បានជិតទេនាងកាលនុងបានពាក់កណ្តាល! ។

កៈ ពាក់កណ្តាល់ចឹងគាត់បានហ៊ានចង់នាំយាយទៅឯណាដែរ?
ខៈ ចង់នាំទៅឯខាងស្រុកយួន។
កៈ អូត្រូវហើយកាលនុង!ព្រោះអីនៅជិតក្នុងយួនដែលនៃសយាយ?
ខៈ អឺម!
កៈ ចឹងគាត់បានរត់ជិតផុតហើយ?
ខៈ
អឺម!បានទៅដល់យួននុងបានផុតហើយតែកាល់នុងបានចូលទៅនុងក៏ជិតបានផុតដែលនាងបានដល់ឯដីក្រហមហើយ!
ដល់ដីក្រហមអានុងវាបានស្ទាក់ផ្លូវដល់ពេលបានស្ទាក់ផ្លូវចឹងវាបានបាញ់ងាប់!ដូចគេគ។
កៈ ហឹម!!!
ខៈ
ហើយខ្ញុំបានដេកនៅក្នុងរន្ធដៅទឹកគេទៅហើយគេទឹកអាជ្រោះដែលហូរហ្នឹងណា។
កៈ ចាស!
ខៈ ខ្ញុំបានដេកជាមួយគ្រួសារក្រោបនុងបានរស់អឺមកនុង។
កៈ ហឹមយាយអើយ!
ខៈ វេទនាណាស់រឿងរបស់ខ្ញុំនោះ។
កៈ ទំរាំតែបានរស់ជីវិត។
ខៈ ចាស!
កៈហឹមមិនដឹងថាកាលនុងបានគុណអីបានជួយយាយ?
ខៈ
បានគុណបុណ្យខ្ញុំបានជួយខ្ញុំបាននឹកគុណដល់គុណម្តាយនិងឪខ្ញុំនឹកគុណព្រះពុទ្ធនិងព្រះធម៌នុងបានដេកហើយបន់នឹកតែចឹង។
កៈហឹម!ហើយមាននរណាគេបានរត់រួចដែរឬទេយាយ?
កាលនុងមិនមែនបានរត់ទៅមួយក្រុមមិនមែនបានរត់ទៅតែយាយណាហេសយាយ?
ខៈ
មិនមែនបានរត់ទៅតែខ្ញុំនោះទេកាលនុងនៅក្នុងព្រៃនុងបានរត់ឡើងរាប់រយប៉ុន្តែដល់តែគេបានលួចរត់ទៅមុនខ្ញុំនោះចឹងក៏គេបានរត់ទៅដល់ស្រុកយួនចឹងទៅហើយចឹងដល់ពេលដែលគេបានដឹងថាយើងនេះបានរត់បុកទៅឯស្រុកយួនចឹងអ្នកខាងនេះវានៅចាំ។
កៈ ហឹម!គេបានដឹងមុខហើយ!។
ខៈ ហ្នឹងហើយ!ដល់ពេលដែលគេបានចាំចឹងទៅគេវានុងបានស្ទាក់យើងបានទៅ!អាណាបានឡើងកាប់អាឫស្សីដើម្បីធ្វើក្បូនឆ្លងទៅស្រុកយួននុងវាបានបាញ់ទំរាំលាក់មកពីចុងឫស្សីមកហើយបានធ្លាក់មកក៏ងាប់ចឹងទៅកាលនៅក្នុងជំនាន់នុងវាលំបាកវេទនាណាស់នាង។
កៈ អូយ!...យាយបានមើលឃើញផ្ទាល់ភ្នែកទៀត។
ខៈ
អឺម!បានដេកជាមួយនិងខ្មោចចឹងទៀតដល់តែពេលយប់ចឹងទៅពួកវាបានថយអស់ចឹងទៅក៏បាននាំកូនដេកនៅក្បែរខ្មោចហ្នឹងទៅ។
កៈ ហឹម!
ខៈ គឺថាទាល់តែដល់ពេលម៉ោង៣ទៀបភ្លឺនោះបាននាំគ្នាដើបដើរទៅទៀតទៅ។
កៈ ហឹម!
ខៈ
ហើយដល់ពេលអាកូននោះវាបានងាប់នៅក្នុងទឹកអាដែងវាបានងាប់ទៅស្រុកយួននុងវាបានហូរចេះមក
ទាល់តែបានគេសដៃចេះបានជាយើងអាចបានដើរទៅរួច។

កៈ ហឺម!យាយអី!ស្រីរណាស់ចឹង! ។
ខៈ
ហើយខ្ញុំនេះវាខ្លាចដល់ចឹងទៅគ្រួសាររបស់ខ្ញុំនេះបានប្រាប់ថាអោយគេសវាចេញទៅបានអាចដើរបានចឹងបានគេសវាចេញទៅបានដើរទៅហើយទឹកឡើងត្រឹមៗហ្នឹងណា។
កៈ ហឹម!
ខៈ បានឆ្លងទៅកាន់ស្រុកវៀតណាមនុង។
កៈ
ហឹម!យាយអើយកាលនុងវាពិបាកណាស់ចឹងកាលនុងហើយចឹងយាយបានឆ្លាប់ឆ្លងកាត់រឿងលំបាកៗចឹងហើយតើយាយមានបានគិតថាអារឿងទាំងអសហ្នឹងយាយមានបានគិតថាតើយាយធ្វើយ៉ាងម៉េចដើម្បីអោយយាយបានធូដែរតើលោកយាយតែងតែធ្វើអ្វី?
ខៈ ថាម៉េចនាង?
កៈ
ដូចថាពេលដែលយាយបានឆ្លងកាត់ការលំបាកអីចឹងមកចឹងពេលខ្លះយាយបាននឹកឃើញវាដែរត្រូវអត់យាយ?
ខៈ នឹកឃើញ! ចៅ!។
កៈ
ចាស!ចឹងយាយបានធ្វើយ៉ាងម៉េចដើម្បីបំបាត់ទុក្ខវាកុំអោយវាដូចថាវាពិបាកសំរាប់បំបាត់វាដែរ?
ខៈ
មិនបានដឹងថាត្រូវធ្វើយ៉ាងម៉េចនោះទេដឹងត្រឹមថាយើងជាមនុស្សស្រីចឹងត្រូវខំប្រឹងតស៊ូណាចៅ! មានតែថាអហោសកម្មអោយដល់គេចុះ! គិតតែប៉ុណ្ណឹងទេ។
កៈ ហឹម!
ខៈ យើងនេះគឺជាស្រីចឹងត្រូវតស៊ូមិនដឹងត្រូវទៅធ្វើម៉េចហ្នឹងកើត! អហោសកម្មអោយដល់វាទៅ។
កៈ
ចាស!ហើយជីវិតរបស់លោកយាយដែលជាការលំបាកជាងគេបំផុតដែលបានធ្វើអោយលោកយាយបាននឹកឃើញមកដល់ពេលឥឡូវនេះនិងយាយមានអ្វីគេខ្លះដែលតើលោកយាយអាចប្រាប់បានដែរឬទេ?
ខៈ
ពិបាកដែលនុងណាចៅដល់តែងាប់ប្តីទៅនឹកឃើញថាមនុស្សវាមិនដែលបានលំបាកពេលមានគ្រួសារនៅជាមួយគ្នាសុខសាន្តអាចដឹងសុខទុក្ខគ្នាដល់មកម៉េម៉ាយកូននៅតូចៗ!វាពិបាកខ្លាំងណាស់នាងវាបានឈឺចាប់ដែរតែមិនបានដឹងថាត្រូវធ្វើយ៉ាងម៉េច?
កៈ
ហឹម!សរសើរដល់លោកយាយដែលបានខំតស៊ូនិងរឹងម៉ាំងណាលោកយាយ។ចឹងអរគុណដល់លោកយាយដែលខំដើម្បីនិងកូនចៅនៅជំនាន់ក្រោយមកទៀតចឹងណាលោកយាយហើយអី!លោកយាយទាក់ទងទៅនិងបទពិសោធន៏របស់លោកយាយចឹងតើលោកយាយមានអ្វីដើម្បីនិងចែកចាយដូចជាតាមរយៈការតស៊ូរបស់លោកយាយចឹងតើលោកយាយចង់អោយកូនចៅជំនាន់ក្រោយយ៉ាងម៉េចដែរទៅលោកយាយ?
ខៈ
សូមផ្តែផ្តាំដល់កូនចៅជំនាន់ក្រោយទាំងអស់!នៅជំនាន់ក្រោយប្រឹងរៀនសូត្រអោយចេះដើម្បីកសាងប្រទេសជាតិអោយបានរីកចំរើនសុខសប្បាយរហូតណាចៅណា! ។
កៈ ហឹម!

ខៈ ខំរៀនខំសូត្រអោយចេះអោយដឹងទៅជាអ្នកស្នងត្រកូល!
នៅស្រុកទេសខាងក្រោយ។ តែប៉ុណ្ណឹងនោះទេចៅ។
កៈ
ចាស!ហើយចឹងជាចុងក្រោយចៅចង់ដឹងថាលោកយាយមានដូចជាបំណង់ប្រាថ្នាទៅអនាគត់ទៅលោកយាយចង់អោយយ៉ាងណាដែរសំរាប់លោកយាយផ្ទាល់?
ខៈ
សំរាប់ខ្ញុំផ្ទាល់អនាគត់ទៅមុខនោះគឺចង់អោយតែកូនចៅសុខសប្បាយប្រទេសជាតិមានសុខសន្តិភាពល្អតែប៉ុណ្ណឹងនោះទេចៅ។
កៈ ចឹងនេះគឺជាបំណង់ប្រាថ្នារបស់លោកយាយ?
ខៈចាសៗ!
កៈ ហើយលោកយាយមានចូលចិត្តមុខម្ហូបអ្វីឬចង់ពិសារអីដែរឬទេលោកយាយ?
ខៈ ខ្ញុំ! មានចង់អីនោះទេសព្វថ្ងៃនេះចឹងណានាងលែងចង់អីហើយ!
សាច់នោះក៏ថុម
ត្រីនោះក៏ថុមបានតែត្រៀមក្រោះអីបន្តិចបន្តួចឬក៏បានមានបន្លែអីចឹងបង់តែប្រហុកអំបិលទៅបានហើយ! អត់មានចង់អីនោះទេនៅពេលឥឡូវនេះនោះ។
កៈ
ចឹងជាចុងក្រោយអរគុណលោកយាយដែលបានចំណាយពេលនៅក្នុងការសម្ភាសហើយចៅសង្ឃឹមថាលោកយាយនិងមានក្រុមគ្រួសារប្រកបដោយសុខភមង្គលហើយនិងបំណង់ប្រាថ្នារបស់លោកយាយនិងទទួលបាននូវដូចជាលោកយាយបានប៉ង់ហើយនិងសូមអោយអី!ទាំងអស់មានគុណបុណ្យដែលលោកយាយបានធ្វើបានដល់កូនរបស់លោកយាយនិងក្រុមគ្រួសារដែលលោកយាយ។
ខៈ សាធុៗ!!ៗ!
កៈ
ចាសលោកយាយចឹងបើសិនជាខាងសាលាគេបានចង់ដាក់សម្លេងរបស់លោកយាយដើម្បីទុក្ខអោយកូនចៅជំនាន់ក្រោយគេបានស្តាប់ណាទាំងរូបថតនិងសម្លេងរបស់លោកយាយ?
ខៈ ខ្ញុំមានថាអីទេនាងដាក់ទៅចុះ។
កៈ ចាស!